ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 01 / 2013
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ អង្គារ ទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៣៤

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| --- |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង (ពេលព្រឹក), កញ្ញា សុង ឆវីន្ត (ពេលរសៀល), លោក Dale LYSAK, លោក William SMITH (ពេលព្រឹក) |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន, អៀង សារី (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZI, លោក Jasper Pauw |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោកស្រី ជេត វណ្ណលី, លោក សំ សុគង់ |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ទឹង សុខា (TCCP-188) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Sonia MESSAOUDI |

| <u>ពេលវេលាទូទៅរបស់តុលាការ៖</u> | | |
|---|---|---|
| ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ៩.៤០ | បញ្ចប់ម៉ោង៖ ១០.២៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៤០ |
| សម្រាកពេលល្ងាច | ចាប់ផ្តើមម៉ោង៖ ១៣.៣៥ | បញ្ចប់ម៉ោង៖ ១៤.៥៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ២៥ នាទី | | |

<u>**កិច្ចដំណើរការនីតិវិធី៖**</u>

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី អៀង សារី ស្នើសុំតាមដានការចូលរួមសវនាការរបស់លោក អៀង សារី | អង្គជំនុំជម្រះ | ៩.១០ | ១០.៥៤ |
| ការកត់សម្គាល់របស់មេធាវីការពារក្តី នួន ជា ទាក់ទងនឹងការបង្ហាញនូវទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី (TCCP-187) | មេធាវីការពារក្តី នួន ជា | ១០.៥៤ | ១១.០៦ |
| ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា (TCCP-188) | អង្គជំនុំជម្រះ<br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១១.០៨<br>១១.១៣ | ១១.១២<br>១៤.៣៣ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ១៤.៣៤<br>១៥.១៣<br>១៥.៤៤<br>១៥.៤៥ | ១៥.១៣<br>១៥.៤៣<br>១៥.៤៤<br>១៥.៤៥ |
| ការថ្លែងពីទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា (TCCP-188) | អង្គជំនុំជម្រះ | ១៥.៤៦ | ១៥.៥៦ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី នួន ជា | ១២.១០ | ១២.១០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី អៀង សារី ស្នើសុំតាមដានការចូលរួមសវនាការរបស់លោក អៀង សារី**

តាមរបាយការណ៍របស់វេជ្ជបណ្ឌិតដែលព្យាបាលលោក អៀង សារី បានបញ្ជាក់ថាលោក អៀង សារី គួរត្រូវបានអនុញ្ញាតិឱ្យចូលរួមសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ។ ជនជាប់ចោទ អៀង សារី បញ្ជាក់ថា គាត់មានបំណងចូលរួមសវនាការដោយផ្ទាល់ មិនមែនពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនោះទេ និងស្នើសុំដកវិញនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់របស់គាត់ដែលបានដាក់កាលពីពេលមុន។ មេធាវីស្នើសុំឱ្យមាននូវការថតខ្សែអាត់វីដេអូ (videotaped) ក្នុងអំឡុងពេលលោក អៀង សារី ចូលរួមសវនាការ ។

សហព្រះរាជអាជ្ញាបញ្ជាក់ថា ជនជាប់ចោទគួរតែត្រូវបានឃ្លាំមើលដោយវេជ្ជបណ្ឌិត ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា វេជ្ជបណ្ឌិតបានផ្តល់នូវអនុស្សាសន៍រួចហើយទាក់ទងនឹងស្ថានភាពរបស់លោក អៀង សារី ហើយអង្គជំនុំជម្រះក៏បានចេញសេចក្តីសម្រេចរួចហើយផងដែរ ។

អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលបានស្នើសុំឱ្យមានការថតខ្សែអាត់វីដេអូ លោក អៀង សារី ក្នុងអំឡុងពេលគាត់តាមដានសវនាការ (សូមមើលសេចក្តីសម្រេចខាងក្រោម) ។

**ការកត់សម្គាល់របស់មេធាវីការពារក្តី នួន ជា ទាក់ទងនឹងការបង្ហាញនូវទុក្ខសោក និងព្យសនកម្ម**

**<u>របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី (TCCP-187)</u>**

មេធាវីការពារក្តី នួន ជា ធ្វើការកត់សម្គាល់ទាក់ទងនឹងការបង្ហាញនូវព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ដែលបានផ្តល់សក្ខីកម្មកាលពីថ្ងៃសុក្រ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ។ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា ទាក់ទងនឹងការសម្រេចសេចក្តីមានលក្ខណៈពីរខុសគ្នា ហើយអាស្រ័យលើប្រភេទនៃបញ្ហានោះ៖បញ្ហាមួយចំនួនគឺត្រូវសម្រេចដោយឆន្ទានុសិទ្ធិរបស់ប្រធាន ហើយបញ្ហាមួយចំនួនផ្សេងទៀតគឺត្រូវសម្រេចដោយអង្គចៅក្រម ។

**<u>ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទឹម សុខា (TCCP-188)</u>**

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនដល់ដើមដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកការតាំងសំណួរបន្តដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា ។ មេធាវីការពារក្តី អៀង សារី, ខៀវ សំផន មិនមានសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ នួន ជា (១២.១០) តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ សម្រាប់ពេលរសៀល។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំរបស់ជនជាប់ចោទ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- **សេចក្តីសម្រេចទាក់ទងនឹងការថតខ្សែអាត់វីដេអូលើជនជាប់ចោទ អៀង សារី៖**

  អង្គជំនុំជម្រះបានសម្រេចថា សេចក្តីសម្រេចទាក់ទងនឹងសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ អៀង សារី គឺផ្អែកទៅលើភស្តុតាង និងសក្ខីកម្មរបស់អ្នកជំនាញដែលមានភាពស៊ីសង្វាក់គ្នា និងពាក់ព័ន្ធគ្នា និងក្រោយពីបានស្តាប់នូវសេចក្តីសន្និដ្ឋានភាគី ។ អ្នកជំនាញបានបង្ហាញថា ស្ថានភាពរាងកាយរបស់លោក អៀង សារី អាចមានការប្រែប្រួលពីពេលមួយទៅពេលមួយ ហើយអង្គជំនុំជម្រះក៏ដឹងពីបញ្ហានេះផងដែរ ហើយអង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការធ្វើឱ្យស្ថានភាពរបស់លោក អៀង សារី

មានសភាពធម្មតា។ អនុលោមតាមបទប្បញ្ញត្តិដែលមានចែងក្នុងវិធាន ៨១(៥) ការទុកឱ្យលោក អៀង សារី នៅក្នុងបន្ទប់សវនាការអាចឈានដល់កម្រិតមួយ ដែលបណ្ដាលឱ្យមានការពន្យាពេលសវនាការយ៉ាងយូ។ អង្គជំនុំជម្រះក៏បានពិចារណាផងដែរនូវរាល់ជំនួយបច្ចេកទេសផ្សេងៗដែលមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដែលអាចជួយដល់ជនជាប់ចោទ រួមទាំងទូរស័ព្ទសម្រាប់ទំនាក់ទំនងជាមួយមេធាវីរបស់គាត់។ទាក់ទងនឹងកាតព្វកិច្ចក្នុងការតាមដាននូវរូបកាយនិងស្មារតីរបស់ជនជាប់ចោទ អង្គជំនុំជម្រះនឹងពឹងផ្អែកទៅលើវេជ្ជបណ្ឌិតដែលព្យាបាលលោក អៀង សារី ដែលត្រូវជូនដំណឹងអំពីការប្រែប្រួលនោះដល់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ការតាមដាននូវស្ថានភាពសុខភាពរបស់លោក អៀង សារី ដោយវេជ្ជបណ្ឌិតនោះគឺតម្រូវឱ្យមាន ហើយការតាមដាននោះមិនមែនធ្វើឡើងដោយចៅក្រម ឬដោយមេធាវីការពារក្ដីខ្លួនឯង ឬដោយសាធារណៈជននោះទេ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើរបស់មេធាវីការពារក្ដី ដែលស្នើសុំឱ្យមានការថតខ្សែអាត់វីដេអូលើរូបលោក អៀង សារី ក្នុងអំឡុងពេលគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួន នៅខាងក្រោមសាលសវនាការនោះ ។

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យជនជាប់ចោទ នួន ជា (១២.១០) ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន (លិខិតលះបង់សិទ្ធិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ) ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្ដឹងរដ្ឋប្បវេណី ទឹង សុខា (TCCP-188) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់ពួកគាត់វិញ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ។
- បង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ អៀង សារី មកកាន់បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ សម្រាប់សវនាការថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ។

| <u>**កាលបរិច្ឆេទបន្តសវនាការ៖**</u> |
|---|
| **សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។** |

ភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារី** Roger PHILLIPS